ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០៥៨ សសរ.

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមការងារទទួលជួប សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករពាក់ព័ន្ធនឹងបញ្ហាដីធ្លី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សេចក្តីសម្រេចលេខ ០២៥ ស.ស.រ. ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការបង្កើតក្រុមការងារទទួលជួប សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករពាក់ព័ន្ធនឹងបញ្ហាដីធ្លី
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ ១.**_

កែសម្រួលសមាសភាពក្រុមការងារទទួលជួប សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករពាក់ព័ន្ធនឹងបញ្ហាដីធ្លី ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ទេព ធន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ឡោ ដាវុធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | អនុប្រធាន |
| ៣. ឯកឧត្តម **សេង ឡូត** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល | អនុប្រធាន |
| ៤. លោក **ទុន្សី វណ្ណារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | សមាជិកអចិន្ត្រៃយ៍ |
| ៥. លោក **ឡាយ ផល្លីម** | ប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ៦. លោក **អេ ប៊ុនធឿន** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៧. លោក **ស៊ូ សុខជា** | ប្រធាននាយកដ្ឋានត្រួតពិនិត្យ និងទទួលពាក្យបណ្តឹង | សមាជិក |



អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

**ប្រការ ២.-**

ក្រុមការងារមានភារកិច្ច ÷

- ទទួលជួបក្រុមអ្នកតវ៉ា ឬក្រុមបាតុករ
- ទទួលញត្តិ និងឯកសារពាក់ព័ន្ធនានាពីក្រុមអ្នកតវ៉ា ឬក្រុមបាតុករ
- សម្របសម្រួល និងដោះស្រាយជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករ
- ស្នើវិធានការដោះស្រាយដើម្បីសុំការសម្រេចពីក្រសួង
- ទំនាក់ទំនងជាមួយក្រុមអ្នកតវ៉ា ឬក្រុមបាតុករដើម្បីទទួលបានព័ត៌មានបន្ថែម និងជូនដំណឹងអំពីដំណោះស្រាយ
- តាមដានការអនុវត្តវិធានការក្នុងការដោះស្រាយរហូតដល់ករណីវិវាទត្រូវបានបញ្ចប់ជាស្ថាពរ និងធ្វើរបាយការណ៍ជូនក្រសួងអំពីវឌ្ឍភាពនៃការដោះស្រាយជាជំហានៗ
- ធ្វើរបាយការណ៍លទ្ធផលប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនក្រសួង។

**ប្រការ ៣.-**

សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្រុមការងារអាចប្រើប្រាស់មន្ត្រីក្រោមឱវាទឱ្យជួយការងារតាមការចាំបាច់។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរ ដនសស រាជធានី ខេត្ត
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ